# កម្មវិធីបណ្តុះបណ្តាលថ្នាក់បណ្ឌិតគ្រប់គ្រងអប់រំ ជំនាន់ទី២

## មេរៀនទី២៖

## ប្រវត្តិ និងការវិវត្តជាបន្តបន្ទាប់នៃប្រព័ន្ធអប់រំនៅកម្ពុជា

(ស្ថានភាពនៃការអប់រំមុនឆ្នាំ១៨៦៣ និងពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៧៩)

បណ្ឌិត នូវ វីរ៉ា
នាយករង វិទ្យាស្ថានជាតិអប់រំ

# ខ្លឹមសារសំខាន់ៗនៃមេរៀន

១. សេចក្តីផ្តើម
២. ស្ថានភាពនៃការអប់រំនៅក្នុងសម័យកាលនីមួយៗ នៃប្រវត្តិសាស្ត្រកម្ពុជា
  ២.១. ការអប់រំនៅមុនសម័យអង្គរ (សតវត្សរ៍ទី១ ដល់ឆ្នាំ៨០២)
    ២.១.១. អាណាចក្រភ្នំ (នគរភ្នំ) ឬហ្វូណន (សតវត្សរ៍ទី១ ឬ គ.ស.ទី១ ដល់ឆ្នាំ៥៥០)
    ២.១.២. អាណាចក្រចេនឡា (សតវត្សរ៍ទី៦ ឬ គ.ស.៥៥០ ដល់ឆ្នាំ៨០២)
  ២.២. ការអប់រំនៅក្នុងសម័យអង្គរ (គ.ស.៨០២ - ១៤៣២)
  ២.៣. ការអប់រំនៅក្រោយសម័យអង្គរ
    ២.៣.១. ការអប់រំនៅក្នុងសម័យលង្វែក និងឧដុង្គ (គ.ស.១៤៣២ - ១៨៦៣)
  ២.៤. ការអប់រំនៅក្នុងសម័យអាណានិគមបារាំង (គ.ស.១៨៦៣ ដល់ឆ្នាំ១៩៥៣)
    ២.៤.១. ការធ្វើទំនើបកម្មសាលាវត្ត (ពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩០៦)
    ២.៤.២. ការបង្កើតប្រព័ន្ធអប់រំផ្លូវការនៅកម្ពុជា (ពីឆ្នាំ១៩០៦ ដល់ឆ្នាំ១៩៥៣)
  ២.៥. ការអប់រំនៅក្នុងសម័យសង្គមរាស្ត្រនិយម (ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧០)
  ២.៦. ការអប់រំនៅក្នុងសម័យសាធារណរដ្ឋខ្មែរ (ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥)
  ២.៧. ការអប់រំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩)
៣. សន្និដ្ឋាន

# វត្ថុបំណងនៃមេរៀន




នៅពេលបញ្ចប់នៃមេរៀននេះ អ្នកសិក្សានឹង៖

១. វិជ្ជាសម្បទា៖

- យល់ដឹង និងពន្យល់បានពីប្រវត្តិ និងការវិវត្តជាបន្តបន្ទាប់នៃប្រព័ន្ធអប់រំនៅកម្ពុជាកាលពីអតីតកាល។

២. បំណិនសម្បទា៖

- បង្ហាញបានពីប្រវត្តិ និងការវិវត្តជាបន្តបន្ទាប់នៃប្រព័ន្ធអប់រំនៅកម្ពុជាកាលពីអតីតកាល។

៣. ចរិយាសម្បទា៖

- ស្គាល់បានច្បាស់ និងមានទឹកចិត្តស្រឡាញ់កាន់តែខ្លាំងក្លាថែមទៀត ចំពោះសកម្មភាពនានាពាក់ព័ន្ធនឹងការងារអប់រំ។

# ១. សេចក្តីផ្តើម

- **ដើមឡើយប្រជាជននៃប្រទេសកម្ពុជាយើង ពុំទាន់មានអក្សរសាស្ត្រដែលត្រឹមត្រូវទៅតាមក្បួនខ្នាតច្បាស់លាស់នៅឡើយទេ។ ឥណ្ឌា បាននាំយកវប្បធម៌ និងអក្សរសាស្ត្រ មានទាំងភាសាសំស្ក្រឹត មកសាបព្រោះនៅប្រទេសកម្ពុជាយើងនាសម័យនោះ។**

- ប្រជាជនខ្មែរយើង បានយកអក្សរឥណ្ឌាមកសរសេរត្រង់ៗតែម្តង ហើយការសិក្សារៀនសូត្រចំណេះវិជ្ជាផ្សេងៗក៏ត្រូវបានសរសេរ និងកត់ត្រាជាអក្សរនេះដែរ។

- **លុះពេលក្រោយមកនៅដើមសតវត្សរ៍ទី១ ដោយសារគំនិតច្នៃប្រឌិត អ្នកប្រាជ្ញខ្មែរបុរាណ ក៏ចាប់ផ្តើមវិចិត្ររចនារូបរាងអក្សរឱ្យមានសភាពរូបលក្ខណៈដាច់ចេញពីរូបរាងដើម និងកែច្នៃដោយការសរសេរអក្សររបស់ខ្លួនឱ្យក្លាយបន្តិចម្តងៗចេញពីអក្សរឥណ្ឌា ហើយនៅទីបំផុតក៏កើតបានទៅជាអក្សរខ្មែរសុទ្ធពេញលក្ខណៈតាមសិល្បៈខ្មែរ។**

(ប្រភព៖ ភិក្ខុ ប៉ាង ខាត់ ១៩៥៩ "វឌ្ឍនភាពនៃការសិក្សាបុរាណ និងវប្បធម៌សំស្ក្រឹតបុរាណ" ស្រាវជ្រាវ និងចងក្រងដោយ ស៊ិន សុវណ្ណនី ២០១០)

## ២. ស្ថានភាពនៃការអប់រំនៅក្នុងសម័យកាលនីមួយៗ នៃប្រវត្តិសាស្ត្រកម្ពុជា

### ២.១. ការអប់រំនៅមុនសម័យអង្គរ (សតវត្សរ៍ទី១ ដល់ឆ្នាំ៨០២)

#### ២.១.១. អាណាចក្រភ្នំ (នគរភ្នំ) ឬហ្វូណាន (សតវត្សរ៍ទី១ ឬ គ.ស.ទី១ ដល់ឆ្នាំ៥៥០)

- នៅប្រទេសកម្ពុជា ការសិក្សាកើតមានឡើងតាំងពីសម័យបុរេប្រវត្តិមកម្លេះ ហើយការសិក្សានេះទទួលឥទ្ធិពលពីសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធ។ យោងតាមប្រភពឯកសារប្រវត្តិសាស្ត្រផ្សេងៗបានសរសេរ និងកត់ត្រាថា ប្រទេសខ្មែរយើងក្នុងសម័យនគរភ្នំមានការសិក្សាច្រើនបែបច្រើនយ៉ាងណាស់ ហើយនៅក្នុងសម័យនោះ ខ្មែរយើងមានសាលាជាន់ខ្ពស់សម្រាប់បង្រៀនវិជ្ជាផ្សេងៗទៀតផង ដូចជាការបង្រៀនអំពី៖ សាសនា រចនារូបភាព តារាសាស្ត្រ ហោរាសាស្ត្រ និងភាសាបរទេសដូចជាភាសាសំស្ក្រឹតជាដើម។ល។

## ២. ស្ថានភាពនៃការអប់រំនៅក្នុងសម័យកាលនីមួយៗ នៃប្រវត្តិសាស្ត្រកម្ពុជា

- ដោយសារការសិក្សាអប់រំមានការរីកចម្រើន ភិក្ខុសាមណេរទាំងឡាយ បានទទួលការសិក្សារហូតដល់កម្រិតខ្ពស់ ហើយមានព្រះថេរអង្គខ្លះដូចជាព្រះមហាថេរ ”សង្ឃបាល” មានចំណេះដឹងខ្ពង់ខ្ពស់ ចេះវិជ្ជាច្រើនប្រការ និងចេះច្រើនភាសាទៀតផង។ តាមឯកសារប្រវត្តិសាស្ត្ររបស់លោកស្រីត្រឹង ងា និងឯកសាររបស់ភិក្ខុប៉ាង ខាត់ វីរិយបណ្ឌិតោ បានបញ្ជាក់ថា សម័យនោះព្រះរាជាខ្មែរបានបញ្ជូនព្រះសង្ឃ២អង្គទៅប្រែព្រះត្រៃបិដកនៅប្រទេសចិន គឺមួយអង្គព្រះនាម “សង្ឃបាល” និងមួយអង្គទៀតព្រះនាម ”មន្ទ្រសេន” នៅដើមគ្រឹស្តសតវត្សទី៦។ ស្នាព្រះហស្ថជាភាសាចិនមានក្តីវិសេសវិសាលណាស់ មិនមាននរណាម្នាក់អាចស្គាល់ថាជាស្នាដៃខ្មែរឡើយ ហើយព្រះចៅក្រុងចិនសព្វព្រះរាជហឫទ័យ និងបានកសាងវត្តប្រគេនសម្រាប់ឱ្យគង់ប្រកបដោយក្តីក្សេមក្សាន្ត។ អ្នកកាន់ព្រះពុទ្ធសាសនាមហាយានក្នុងសាកលលោក ស្គាល់ព្រះនាមព្រះអង្គច្បាស់ណាស់។ គេមានចារឹកព្រះនាមព្រះថេរទាំងពីរអង្គនៅក្នុងព្រះត្រៃបិដកចិនរហូតដល់បច្ចុប្បន្ន។ កេរ្តិ៍ឈ្មោះប្រទេសកម្ពុជា អណ្តែតត្រសែតខ្ពង់ខ្ពស់ណាស់ដោយព្រះថេរទាំងពីរអង្គនេះរហូតដល់សព្វថ្ងៃ។

## ២.១.២. អាណាចក្រចេនឡា (សតវត្សរ៍ទី៦ ឬ គ.ស.៥៥០ ដល់ឆ្នាំ៨០២)

- នៅសម័យចេនឡា ការសិក្សាមានភាពរីកចម្រើនខ្លាំងបន្តពីសម័យអាណាចក្រភ្នំ និងមានការសិក្សាកម្រិតខ្ពស់ផ្នែកភាសាសំស្ក្រឹតពីសំណាក់ខ្សែរាជវង្ស និងមន្ត្រីតូចធំ។
- ប្រទេសខ្មែរកាលពីសម័យនោះក៏សម្បូរទៅដោយកវីឯក អ្នកនិពន្ធ និងអ្នកប្រាជ្ញមួយចំនួនផងដែរ។
- នៅសម័យចេនឡា ទន្ទឹមនឹងភាសាសំស្ក្រឹត ភាសាខ្មែរបុរាណ ក៏ត្រូវបានគេយកមកប្រើប្រាស់នៅក្នុងសិលាចារឹកដែរ។ សិលាចារឹកខ្មែរដំបូងដែលចុះកាលបរិច្ឆេទច្បាស់លាស់គឺ ″សិលាចារឹកអង្គរបុរី″ (គ.ស. ៦១១) មានដូចជា សិលាចារឹក (១) រឿងរាមាយណៈ (២) រឿងមហាភារតៈ និង (៣) គម្ពីរខ្មែរបុរាណ។

## ២.២. ការអប់រំនៅក្នុងសម័យអង្គរ (គ.ស.៨០២ - ១៤៣២)

- ការសិក្សាអប់រំនាសម័យនោះឡើងដល់កម្រិតកំពូល ហើយមានអ្នកប្រាជ្ញ បណ្ឌិត និងសាស្ត្រាចារ្យ ដែលជាអ្នកទ្រទ្រង់ការសិក្សាក៏កាន់តែច្រើនថែមទៀត ដែលក្នុងនោះអ្នកប្រាជ្ញខ្លះខាងផ្នែកព្រះពុទ្ធសាសនា អ្នកប្រាជ្ញខ្លះផ្នែកព្រាហ្មណ៍សាសនា ខ្លះជាបុរោហិត និងខ្លះទៀតជាព្រះរាជគ្រូ។ រីឯស្នាដៃរបស់អ្នកប្រាជ្ញទាំងអស់នោះ មានតម្លៃកាត់ថ្លៃពុំបាន សូម្បីកវីព្រាហ្មណ៍ដែលនៅក្នុងប្រទេសឥណ្ឌា ក៏ពុំអាចប្រៀបផ្ទឹម ឬយកឈ្នះបានឡើយ។
- នៅក្នុងរាជជំណាក់ មានមហាវិទ្យាល័យជាន់ខ្ពស់សម្រាប់ព្រះរាជត្រកូលនៅក្នុង ″វត្តជ័យស្រី″ (ក្នុងប្រាសាទព្រះខ័ន) ដែលព្រះនាងឥន្ទ្រទេវីជាព្រះអគ្គជាយានៃព្រះបាទជ័យវរ្ម័នទី៧ ហើយទ្រង់ជាសាកលវិទ្យាធិការិនី។
- លោកជីតាក្វាន់ បានបញ្ជាក់ថា ចំណែកក្មេងៗ កូនអ្នកស្រុកដែលត្រូវការរៀនសូត្រ គេតែងយកទៅទុកដាក់ឲ្យរៀន និងទទួលការអប់រំជាមួយព្រះសង្ឃ។ កាលបើចេះដឹង និងធំឡើង កូនអ្នកស្រុកទាំងនោះក៏បួសជា សង្ឃ។ លុះដល់អាយុច្រើន គេក៏វិលត្រឡប់ទៅកាន់ជីវភាពជាជនធម្មតាវិញ។

## ២.៣. ការអប់រំនៅក្រោយសម័យអង្គរ

- ការសិក្សាអប់រំនៅក្រោយសម័យអង្គរ ពោលគឺពីសតវត្សទី១៤-១៨ មានការចុះទន់ខ្សោយក៏ពិតមែនក៏ប៉ុន្តែការសិក្សាអប់រំនោះ នៅតែមានសកម្មភាពជាបន្តបន្ទាប់ និងរក្សាបាននូវភាពគង់វង្សរហូតមក។
- នៅសម័យក្រោយអង្គរ សាសនាព្រាហ្មណ៍ បានសាបរលាបទៅបន្តិចម្តងៗ ហើយជំនួសមកវិញដោយសាសនាព្រះពុទ្ធ។
- កូនចៅខ្មែរយើងបានទៅនៅទីវត្តអារាម ព្រោះថាវត្តគឺជាសាលារៀនហើយព្រះសង្ឃឬចៅអធិការជាគ្រូបង្រៀន។ វត្តត្រូវបានគេចាត់ទុកជាជង្រុក ឬជាឃ្លាំងដែលផ្ទុកនូវវិជ្ជាផ្សេងៗមានដូចជាអក្សរសាស្ត្រ គណិតសាស្ត្រ ហោរាសាស្ត្រ វេជ្ជសាស្ត្រ និងសិល្បសាស្ត្រ។ល។
- កូនខ្មែរជំនាន់នោះ សុទ្ធតែជាសិស្សវត្ត ទទួលការសិក្សាអប់រំពីវត្ត និងពីព្រះសង្ឃដែលជាគ្រូ ហើយពេលសិក្សារៀនសូត្រចប់ និងចេញពីវត្តទៅ ពួកគេអាចក្លាយខ្លួនជាព្រះមហាក្សត្រ សេនាបតី នាម៉ឺន ឬមន្ត្រី កាន់តួនាទីនៅក្នុងប្រទេស ក្នុងក្រសួង ឬក្នុងស្ថានប័ននានា។

## ២.៣.១. ការអប់រំនៅក្នុងសម័យលង្វែក និងឧដុង្គ (គ.ស.១៤៣២ - ១៨៦៣)

- ដូចបានលើកឡើងរួចមកហើយថា សម័យក្រោយអង្គរ គឺជាសម័យកាលដែលខ្មែរយើងបានធ្លាក់ចុះដុនដាបគ្រប់វិស័យ និងគ្រប់ផ្នែក៖ ទាំងសេដ្ឋកិច្ច នយោបាយ វប្បធម៌ បរិស្ថាន និងការសិក្សាអប់រំ ដោយសារទំនាស់ក្នុងរាជវង្ស ទំនាស់ក្នុងជួរមន្ត្រីរាជការ និងបញ្ហាសង្គ្រាមឈ្លានពានរបស់ប្រទេសជិតខាង។ តាមប្រវត្តិសាស្ត្រ សម័យក្រោយអង្គរ ត្រូវបានបែងចែកជាបីដំណាក់កាលគឺ៖
  (១) ដំណាក់កាលចតុមុខ-លង្វែក ឬភ្នំពេញ-លង្វែក (១៤៣២ ដល់ ១៥៩៥)
  (២) ដំណាក់កាលឧដុង្គ (នៅស.វ.ទី១៧ និង១៨) និង
  (៣) ដំណាក់កាលនៃការស្តារប្រព័ន្ធអប់រំឡើងវិញក្នុងរជ្ជកាលព្រះបាទអង្គឌួង (គ.ស. ១៨៤៨- ១៨៦០ )។

- ការសិក្សាអប់រំពេលនោះមានលក្ខណៈទន្និញចាំមាត់ គ្មានគោលវិធី ឬគោលការណ៍គរុកោសល្យអ្វីឡើយ ហើយការសិក្សាអប់រំផ្តោតលើច្បាប់ដំបូន្មាន ការអាន ការសរសេរភាសាខ្មែរ គម្ពីរព្រះពុទ្ធសាសនា ច្បាប់កម្មសិទ្ធិ និងលេខនព្វន្តមួយចំនួន។ គ្មានការរៀបចំកម្មវិធីសិក្សា និងម៉ោងសិក្សារៀនសូត្របានច្បាស់លាស់ទេ ហើយក៏គ្មានការប្រឡងប្រជែងអ្វីទាំងអស់ដែរ ចំណែកគ្រូបង្រៀនក៏គ្មានការបណ្តុះបណ្តាលឱ្យបានត្រឹមត្រូវដែរ។

## ដំណាក់កាលទី១៖ ដំណាក់កាលចតុមុខ-លង្វែក ឬភ្នំពេញ-លង្វែក (១៤៣២ ដល់ ១៥៩៥)

- ក្រុងលង្វែក ត្រូវបានសៀមវាយបែកក្នុងឆ្នាំ១៥៩៤ ហើយអ្នកប្រាជ្ញ កវី បណ្ឌិត សាស្ត្រាចារ្យ និងអ្នកចេះដឹងជាច្រើនរូបទៀត ត្រូវបានសៀមចាប់ខ្លួន ឃុំខ្លួន ឬសម្លាប់ចោល និងមួយចំនួនបានភៀសខ្លួនគេចទៅនៅស្រុកសៀម។ ការសិក្សាអប់រំបានធ្លាក់ចុះខ្លាំង ព្រោះស្នាដៃអក្សរសិល្ប៍ ក្រាំង សាស្ត្រាស្លឹករឹត ព្រមទាំងឯកសារផ្សេងៗទៀតដែលជាសម្បត្តិមហាសាលរបស់ខ្មែរ ត្រូវបានបំផ្លាញ ខូចខាត និងវិនាសខ្ទេចខ្ទីស្ទើរតែទាំងអស់។ សាស្ត្រាជំនាន់អង្គរជាច្រើន ត្រូវបានបាត់បង់ ខ្លះទៀតត្រូវគេប្រមូលយកទៅទីក្រុងអយុធ្យា ហើយមួយចំនួនទៀតត្រូវភ្លើងឆេះនៅពេលដែលភូមាបានវាយចូលលុកលុយ និងដុតបំផ្លាញទីក្រុងអយុធ្យាក្នុងឆ្នាំ១៧៦៧។

## ដំណាក់កាលទី២៖ ដំណាក់កាលឧដុង្គ (នៅស.វ.ទី១៧ និង១៨)

- ប្រទេសកម្ពុជា បានធ្លាក់ចុះទៅក្នុងកលិយុគចាប់ពីឆ្នាំ១៧៧៦ ដល់១៨៦០។ ក្នុងអំឡុងស.វ.ទី១៩ នៅពេលដែលមានជម្លោះក្នុងការដណ្ដើមកាន់កាប់ត្រួតត្រាកម្ពុជាពីសំណាក់ពួកសៀម និងយួន វប្បធម៌ខ្មែរសឹងផុតរលត់ព្រោះថាវត្តអារាមត្រូវបានកម្ទេច និងដុតបំផ្លាញចោល។ កម្ពុជានៅពេលនោះ ខ្វះអ្នកប្រាជ្ញ និងមន្ត្រីដែលមានសមត្ថភាព និងភាពក្លាហានដែលអាចជួយសង្គ្រោះប្រទេសជាតិឱ្យរួចចាកផុតពីគ្រោះមហន្តរាយបាន។ ប្រព័ន្ធសិក្សាអប់រំក៏បានធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ។

## ដំណាក់កាលទី៣៖ ការស្តារប្រព័ន្ធអប់រំឡើងវិញក្នុងរជ្ជកាលព្រះបាទអង្គឌួង (គ.ស. ១៨៤៨- ១៨៦០ )

- ព្រះបាទអង្គឌួង បានខិតខំប្រឹងប្រែងក្នុងការស្តារ និងកសាងប្រព័ន្ធអប់រំខ្មែរឡើងវិញ។ ព្រះអង្គបានចាត់ទុកវិស័យព្រះពុទ្ធសាសនាជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យមានសន្តិភាព និងការរស់ឡើងវិញនៃកម្ពុជា។ ការសិក្សាអប់រំក្នុងរជ្ជកាលព្រះអង្គរួមមាន៖
  - ✓ ការកសាងឡើងវិញនូវបណ្ណាល័យ
  - ✓ ការប្រមូលគម្ពីរព្រះពុទ្ធសាសនាដែលបានបាត់បង់ ឬក៏ត្រូវបានបំផ្លាញក្នុងអំឡុងពេលសង្គ្រាម
  - ✓ ការប្រមូលកុមារឱ្យចូលរៀននៅតាមសាលាវត្ត
  - ✓ ការផ្តល់អាហារូបករណ៍ដល់យុវជនដើម្បីសិក្សាភាសាបរទេស និង
  - ✓ ការរៀនសូត្រភាសាបាលី និងគម្ពីរព្រះត្រៃបិដក។
- បន្ទាប់ពីការដួលរលំនៃសម័យអង្គរ ទីអារាមព្រះពុទ្ធសាសនាបានក្លាយជាមជ្ឈមណ្ឌលសិក្សារៀនសូត្រ និងក្លាយទៅជាទីកន្លែងសម្រាប់ថែរក្សា និងអភិរក្សវប្បធម៌ ហើយបព្វជិតព្រះពុទ្ធសាសនាគឺតំណាងឱ្យបញ្ញាជនកម្ពុជា។
- ប្រព័ន្ធអប់រំខ្មែរសម័យក្រោយអង្គរ គឺជាប្រព័ន្ធអប់រំបែបព្រះពុទ្ធសាសនា។ វត្តអារាមមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សឱ្យមកបម្រើការងារនៅក្នុងរាជការ។ ភាសាយាន គឺភាសាបាលីដែលជាភាសាកម្រិតខ្ពស់ និងភាសាខ្មែរដែលជាភាសាសម្រាប់ប្រជាជនសាមញ្ញ។

- ព្រះបាទអង្គឌួង ជាអ្នកប្រាជ្ញ ជាកវី ជាបណ្ឌិត ជាអ្នកនិពន្ធ និងជាសាស្ត្រាឯក។ សម័យនោះរាជធានីឧដុង្គជាសាកលវិទ្យាល័យ និងទ្រង់ជាសាកលវិទ្យាធិការ ហើយទ្រង់បង្រៀន៖ អក្សរសាស្ត្រខ្មែរ វិជ្ជាកាព្យ វិជ្ជានិពន្ធ ភាសាបាលី ធម៌ ទស្សនវិជ្ជាពុទ្ធសាសនា និង វិជ្ជាផ្សេងៗទៀតដោយផ្ទាល់ព្រះអង្គ។
- ការអប់រំតាមពុទ្ធសាសនា ផ្តោតលើការរៀនសូត្រព្រះត្រៃបិដក ច្បាប់ស្នាដៃអក្សរសិល្ប៍ និងគម្ពីរសាស្ត្រានានា។ អ្នកប្រាជ្ញ និងកវីនិពន្ធល្បីៗ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សំគ្រឿង និងការដាំស្លឱ្យអក្សរសិល្ប៍ពុទ្ធនិយម និងអរិយធម៌ខ្មែរមានភាពសម្បូណ៌បែប។
- ក្នុងរជ្ជកាលព្រះអង្គ ព្រះពុទ្ធសាសនាថេរវាទឬហីនយាន សិល្បៈ អក្សរសាស្ត្រ និងវប្បធម៌បានរស់រានមានជីវិតឡើងវិញ ហើយចលនាអក្ខរកម្មភាសាខ្មែរមានវិបុលភាពជាខ្លាំង។ ស្នាព្រះហស្តរបស់ព្រះអង្គមាន៖ រឿងចម្ប៉ាថោង (១៨១០) រឿងកាកី (១៨១៥) និងច្បាប់ស្រី (១៨៣៧)។

# កំណត់សម្គាល់ពិសេសចំពោះការលះបង់របស់ព្រះបាទអង្គឌួង

- ជារៀងរាល់យប់ ព្រះអង្គបានធ្វើសមាធិនៅពាក់កណ្ដាលអធ្រាត្រ និងបានបរិច្ចាគព្រះរាជទ្រព្យមួយផ្នែកធំដើម្បីលោះខ្ញុំបម្រើ (ចំនួន៣៥០នាក់) និងផ្ដល់ការឧបត្ថម្ភគាំទ្រដល់ព្រះសង្ឃ និងអ្នកចេះដឹងទាំងឡាយ។
- នៅឆ្នាំ១៨៦០ ពេលដែលព្រះអង្គចាប់ផ្ដើមប្រឈួនយ៉ាងខ្លាំង ព្រះអង្គបានចេញព្រះរាជបញ្ជាឱ្យគេដោះលែងខ្ញុំបម្រើដើម្បីជាការធ្វើបុណ្យសន្សំកុសល។
- ព្រះអង្គបានបង្ហាញនូវបំណងប្រាថ្នាថា**នៅពេលព្រះអង្គសោយទីវង្គត សុំឱ្យគេកាត់សាច់របស់ព្រះអង្គចេញពីព្រះកាយ ហើយឱ្យសត្វស៊ីជាអាហារ។**
- គេបានធ្វើតាមព្រះរាជបណ្ដាំរបស់ព្រះអង្គ ហើយកាំបិតដែលគេប្រើសម្រាប់កាត់សាច់របស់ព្រះអង្គនោះត្រូវបានគេប្រសិទ្ធីដោយទឹកមន្តដែលបានធ្វើឡើងដោយព្រះសង្ឃជាច្រើនអង្គ។ បន្ទាប់មកសាច់របស់ព្រះអង្គត្រូវបានគេដាក់លើថាសពណ៌មាសជាច្រើនដើម្បីឱ្យសត្វបក្សីចឹកស៊ីជាចំណី។ មានសាក្សីជាច្រើនបានឃើញព្រឹត្តិការណ៍នោះ ហើយសាក្សីម្នាក់ក្នុងចំណោមសាក្សីជាច្រើនគឺលោកឡឺក្លែរ (Adhémard Leclère) បានឃើញពិធីនោះផ្ទាល់ភ្នែកនៅចុងសតវត្សរ៍នោះ ហើយលោកជឿថាពិធីបែបនោះបានកើតឡើងជាធម្មតាកាលពីអតីតកាល។

# រួមសេចក្តីមក ការអប់រំមុនឆ្នាំ១៨៦៣ មិនមានស្តង់ដាច្បាស់លាស់ទេ

មុខពេលប្រទេសកម្ពុជា បានក្លាយទៅជាប្រទេសនៅក្រោមអាណាព្យាបាលបារាំង និងក្រោយមកបានក្លាយទៅជាប្រទេសនៅក្រោមអាណានិគមបារាំងក្នុងឆ្នាំ១៨៦៣ ការអប់រំតាមបែបប្រពៃណី ត្រូវបានប្រជាជននិយមសិក្សា និងប្រតិបត្តិនៅតាមទីវត្តអារាមដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្ររស់នៅរបស់ពួកគេ ហើយព្រះសង្ឃ និងចៅអធិការវត្ត គឺជាគ្រូបាអាចារ្យនៅក្នុងការសិក្សាអប់រំនោះ (Clayton, 1995)។ បើតាមកវីម្ចាស់ស្នឹងសង្កែលោកគង់ ប៊ុនឈឿន (២០០១) ខ្មែរយើងកាលពីសម័យដើមតែងតែយកកូនៗជាពិសេសកូនប្រុស ឱ្យទៅទទួលការសិក្សាអប់រំពីព្រះសង្ឃ ឬព្រះចៅអធិការនៅក្នុងសាលាវត្តដែលមាននៅក្នុងភូមិ ឬក្បែរៗភូមិដែលពួកគេរស់នៅ។

## A. Educational situations prior to 1983

(Not standardized)

Before Cambodia became a French protectorate in 1863, traditional education in Cambodia had been handled by the local Wat (Temples or Pagodas), and the Buddhist Monks were the teachers. (Clayton, 1995).

The primitive Khmer, according to Bunchoeun, K. (2001), always brought their children, especially males, to have education from Buddhist monks in Wat-schools.

ហេតុផលបីយ៉ាងដែលមាតាបិតា និងអាណាព្យាបាល ជឿថាកូនស្រីមិនត្រូវបានលើកទឹកចិត្តឱ្យទទួលបាននូវការអប់រំគឺ៖

1. កូនស្រី ឬស្ត្រី មានកម្លាំងខ្សោយជាងកូនប្រុស ឬបុរស។ ដូច្នេះពួកគេសមតែធ្វើកិច្ចការណាដែលស្រាលៗដូចជា មើលថែទាំកូន តុបតែងនិងរៀបចំផ្ទះសម្បែងឱ្យមានសណ្តាប់ធ្នាប់ និងចម្អិនម្ហូបអាហារសម្រាប់គ្រួសារ។
2. ការអប់រំ និងការសិក្សាគឺនៅក្នុងវត្តអារាម ជាទីកន្លែងដែលព្រះសង្ឃ ឬអ្នកបួសសំណាក់ធម៌។ បើតាមគោលការណ៍ទ្រឹស្តីព្រះពុទ្ធសាសនា កូនស្រី ឬស្ត្រីមិនត្រូវបានគេអនុញ្ញាតឱ្យនៅជិត ឬប៉ះពាល់ដោយព្រះសង្ឃ ឬអ្នកបួសបានទេ។
3. ប្រជាជនខ្មែរភាគច្រើននាសម័យនោះ មានជំនឿយ៉ាងមុតមាំថា បើកូនស្រីចេះអក្សរ ពួកគេនឹងសរសេរសំបុត្រស្នេហាទៅកាន់សង្សារ ដែលជាហេតុនាំខូចកេរ្តិ៍ឈ្មោះកិត្តិយស និងរឿងអាស្រូវផ្សេងៗមកឱ្យគ្រួសារ។

**The reasons, believed by the then parents and communities, why females were not encouraged to have education were that:**

- females were weaker than males in terms of physical abilities. Thus, they deserved doing just only light things such as looking after children, decorating inner or outer parts of houses, putting things in order, and preparing food for the families,
- learning was taking place in Wats, the place where ordained monks were staying or meditating. According to the principles of Buddhism, females were not allowed to be near or touched by monks, and
- the majority of the then people strongly believed that if their daughters were literate, they would write love letters to their boyfriends, and that would bring shames, bad reputations, and scandals to the families.

## ២.៤. ការអប់រំនៅក្នុងសម័យអាណានិគមបារាំង (គ.ស.១៨៦៣ ដល់ឆ្នាំ១៩៥៣)

- ចាប់តាំងពីថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ប្រទេសខ្មែរស្ថិតនៅក្រោមអាណានិគមបារាំង។ នៅដើមសម័យនោះ ការសិក្សាអប់រំមានលក្ខណៈស្រដៀង និងដូចការសិក្សាអប់រំក្នុងសម័យលង្វែក សម័យឧដុង្គ និងសម័យព្រះបាទអង្គឌួងដែរ ដោយប្រើប្រាស់ឯកសារសម្រាប់ការរៀន និងការបង្រៀនតាមសាស្ត្រាស្លឹករឹតដែលមាននៅសេសសល់ពីការដុតបំផ្លាញដោយសង្គ្រាមឈ្លានពាន ពីការរឹបអូស លួច ធក់ប្លន់ និងដឹកជញ្ជូនចេញពីសំណាក់ប្រទេសជិតខាងរបស់ខ្មែរយើង។
- ការសិក្សាអប់រំនៅសម័យដែលបារាំងគ្រប់គ្រង មិនសូវមានការរីកចម្រើនប៉ុន្មានទេ ប៉ុន្តែនៅពេលក្រោយមក គេឃើញថាបារាំងបានយកប្រព័ន្ធអប់រំថ្មីមកបំពាក់បន្ថែមលើការសិក្សាអប់រំបែបប្រពៃណីរបស់ខ្មែរ។
- ការសិក្សាតាមបែបប្រពៃណី គឺការបួសរៀននៅក្នុងវត្តអារាមនានាក៏នៅតែបន្តតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការជួយសង្គ្រោះកូនខ្មែរឱ្យបានរួចចាកផុតពីភាពអវិជ្ជា។ ព្រះសង្ឃនៅតែមាននាទីជាគ្រូអាចារ្យដ៏សំខាន់ក្នុងការជួយបង្ហាត់បង្រៀននូវវប្បធម៌ ប្រពៃណី និងអក្សរសាស្ត្រខ្មែរដល់កូនខ្មែរនាពេលនោះ។

## ២.៤.១. ការសិក្សាអប់រំតាមបែបប្រពៃណី

- ផ្អែកតាមឯកសាររបស់លោក លី ធាមតេង (១៩៦៩:១៦០) ប្រជាជនខ្មែរនាពេលនោះ បានបញ្ជូនកូនចៅឱ្យទៅរៀននៅវត្តដែលជាមជ្ឈមណ្ឌលដ៏សំខាន់សម្រាប់ការអប់រំ។ វត្តអារាមនៅតែជាកន្លែងសម្រាប់អប់រំដែលមានព្រះសង្ឃជាគ្រូអាចារ្យសម្រាប់បង្ហាត់បង្រៀន។ ព្រះសង្ឃខ្មែរនាពេលនោះសុទ្ធតែមានសេចក្តីមេត្តាយ៉ាងក្រៃលែង ក្នុងការប្រឹងប្រែងបង្ហាត់បង្ហាញកុមារទាំងឡាយលុះត្រាតែចេះអាន ចេះសរសេរល្មម អាចប្រើការបាន ទើបអនុញ្ញាតឱ្យវិលត្រឡប់មកផ្ទះវិញ ដើម្បីរកប្រកបអាជីវកម្មតទៅថ្ងៃមុខ ។
- តាមឯកសារលោកមៀច ប៉ុណ្ណ (២០០៧:៣៥) ការរៀនសូត្រមាន៤ដំណាក់កាលសំខាន់ៗ គឺ (១) ដំបូងកុមារត្រូវរៀនអាន និងសរសេរ (២) ក្រោយមកត្រូវរៀនមើលសាស្ត្រាច្បាប់ (ដូចជាច្បាប់ព្រះរាជសម្ភារ ច្បាប់ប្រុស ច្បាប់ស្រីជាដើម) (៣) ក្រោយមកទៀតគេត្រូវរៀនមើលសាស្ត្រាល្បែង (ប្រលោមលោកសម័យបុរាណដែលគេសរសេរជាកំណាព្យដូចជាសាស្ត្រាជុច ហង្សយន្ត និងសព្វសិទ្ធិជាដើម) និង (៤) ចុងក្រោយគេត្រូវរៀនមើលសាស្ត្រាទេសន៍ (រួមមានទសជាតក៍ជាដើម)។

## (១) ការរៀនអាន និងសរសេរ

- កុមារមានអាយុចន្លោះពី៧ទៅ១០ឆ្នាំ ត្រូវបានមាតាបិតានាំទៅសិក្សានៅវត្ត ដោយរើសយកថ្ងៃណាដែលល្អ។ គេច្រើនពេញចិត្តថ្ងៃព្រហស្បត្តិ៍ ព្រោះថ្ងៃនេះជាទេវតាសម្ដី ហើយគេជឿថាកុមារចាប់ផ្ដើមរៀនថ្ងៃនេះនឹងឆាប់ចេះឆាប់ដឹង។ ពេលរើសថ្ងៃល្អបានហើយ ពេលព្រឹកមាតារៀបចំអាហារទុកជាចង្ហាន់ប្រគេនព្រះសង្ឃ ហើយស្វាមីភរិយានាំកូនទៅវត្តចូលទៅលោកគ្រូចៅអធិការ ក្រាបបង្គុំបីដង រួចបង្គាប់ឲ្យកូនថ្វាយបង្គុំបីដង ហើយលើកភោជនាអាហារប្រគេនព្រះសង្ឃ ទើបថយមករកទីគួរសមអង្គុយ លើកដៃប្រណម្យទូលថា ៉ព្រះតេជគុណម្ចាស់! ខ្ញុំព្រះករុណាទាំងពីរនាក់ នាំកូននេះឈ្មោះ... មកប្រគេនទុកជាសិស្សឲ្យសិក្សាចំណេះវិជ្ជា មានអក្សរ លេខជាដើម។ សូមព្រះតេជគុណមេត្តាប្រោសបង្ហាត់បង្រៀនច្បាប់លោក ច្បាប់ធម៌ ចំណេះវិជ្ជាគ្រប់ប្រការឲ្យទាន។ ខ្ញុំព្រះករុណាទាំងពីរនាក់សុំតែភ្នែក និងឆ្អឹងទេ (មានន័យថា កុំឲ្យខ្វាក់ភ្នែក និងបាក់ឆ្អឹង) សាច់ឈាមប្រគល់ជូនព្រះតេជគុណទាំងអស់ (ពាក្យនេះមានន័យថា សូមបង្រៀនវិជ្ជាសព្វសារពើ បើទាស់ខុសឆ្គងត្រង់ណា កាយ ឬវាចាចិត្ត មេត្តាប្រោសពុតប្រដៅឲ្យទាន ឲ្យទាល់តែបានជាមនុស្សដឹងក្ដីឡើង។ និយាយទូលលោកហើយ បែរមកនិយាយនិងកូនថា៉កូន! ម៉ែឪ នាំឯងមកប្រគេនព្រះតេជគុណឲ្យសិក្សារៀនសូត្រ។ ត្រូវប្រតិបត្តិព្រះតេជគុណកុំបីឲ្យមានឆ្គង មើលបម្រើទឹកក្ដៅទឹកត្រជាក់តាមការគួរ ហើយខំប្រឹងប្រែងរៀនសូត្រឲ្យបានចេះដឹង ឲ្យម៉ែឪសប្បាយចិត្ត ធ្វើឲ្យវង្សត្រកូលថ្កុំថ្កើងរុងរឿងតទៅ៉។

## (២) រៀនមើលសាស្ត្រាច្បាប់

- ការរៀនមើលសាស្ត្រាច្បាប់នេះ គឺរៀនមើលជាពាក្យរាយ មិនឲ្យមើលជាបទតាមច្បាប់ទេ (សាស្ត្រាច្បាប់ទាំងអស់សុទ្ធតែជាពាក្យ ដូចជាសាស្ត្រាច្បាប់ក្រម ច្បាប់កេរកាល ច្បាប់ប្រុស ច្បាប់ស្រី រាជនេតិ ច្បាប់ព្រះរាជសម្ភារ ។ល។
- លោកគ្រូនាំសិស្សរៀនអាន ឲ្យបានត្រឹមត្រូវច្បាស់លាស់តាមតួអក្សរ។ រួចសិស្សរៀនអានដោយខ្លួនឯងតទៅទៀត អានហើយអានទៀត សារចុះសារឡើងទាល់តែរត់មាត់ ចាំមាត់ទទេមិនចាច់មើលអក្សរក៏បាន។
- ក្នុងការផ្ទៀងមើល លោកគ្រូនិមន្តទៅគង់ជិត ហើយបង្គាប់ឲ្យសិស្សចាប់សាស្ត្រាអាន អានតាំងពីដើមដល់ចប់។ បើលោកឃើញថា សិស្សនេះចេះអានស្ទាត់ជំនាញហើយ លោកគ្រូពន្យល់សេចក្ដីក្នុងសាស្ត្រាច្បាប់នោះទៀត ទើបលោកឲ្យឡើងទៅមើលសាស្ត្រាល្បែងទៀត។

## (៣) រៀនមើលសាស្ត្រាល្បែង

- ការរៀនមើលសាស្ត្រាល្បែង  មានទម្រង់ដូចនឹងការមើលសាស្ត្រាច្បាប់ដែរ។  តែម្តងនេះលោកគ្រូឲ្យរៀនជាបទ ព្រោះសាស្ត្រាល្បែងទាំងអស់ជាបទ គឺបទកាកគតិ ព្រហ្មគីតិ ភុជង្គលីលា ពំនោល ។ល។
- សាស្ត្រាល្បែងមានច្រើនច្បាប់ដូចជា សាស្ត្រាសុបិន ហង្សយន្ត វិមានច័ន្ទ សង្ខ័សិល្ប៍ជ័យ សព្វសិទ្ធិ ។ល។
- លោកគ្រូបង្រៀនឲ្យមើលតាមបទ  សិស្សថាតាមបទ។  បន្ទាប់មកទៀត  សិស្សរៀនមើលដោយខ្លួនឯង  មើលដដែលៗ ហើយផ្លាស់ពីសាស្ត្រាមួយ ទៅសាស្ត្រាមួយទៀត ទាល់តែអស់សាស្ត្រាដែលមាននៅក្នុងវត្ត។
- លោកគ្រូផ្ទៀងមើល  បើឃើញថាសិស្សចេះអានបទត្រឹមត្រូវហើយ  ទើបលោកឲ្យឡើងឲ្យមើលសាស្ត្រាទេសន៍ទៀត។

## (៤) ការរៀនមើលសាស្ត្រាទេសន៍

- ការរៀនមើលសាស្ត្រាទេសន៍ មានការអានផ្សេងៗពីសាស្ត្រាល្បែងជាបទ ឬជាពាក្យរាយធម្មតា។ សាស្ត្រាទេសន៍ ជាសេចក្តីមួយបែបនៅក្នុងពាក្យរាយដែរ ប៉ុន្តែមិនមែនជាពាក្យរាយធម្មតាទេ ជាពាក្យរាយដូចគ្នា ជួនរណ្តំគ្នា រដឹកគ្នា។ ដូចនេះ លោកគ្រូបង្រៀនឲ្យសិស្សរៀនតាមបែបទេសន៍ គេហៅថារៀនទេសន៍។ សាស្ត្រាទេសន៍មានច្រើនច្បាប់៖ សាស្ត្រាអានិសង្ឃ អានិសង្ឃចម្លងបុណ្យ អានិសង្ឃខ្មោច រហូតដល់សាស្ត្រាទេសន៍ធំៗដូចជា ទសជាតក៏ជាដើម។ សិស្សរៀនដល់ថ្នាក់នេះ ទុកជាសិស្សជាន់ខ្ពស់ហើយ។
- អ្នកនិពន្ធសាស្ត្រាទេសន៍ សុទ្ធតែជាអ្នកមានស្នាដៃប្រសើរ ពាក្យពេចន៍ខ្ពស់ ពាក្យរាយជួនរណ្តំគ្នា មើលទៅមិនអាក់ ពិរោះស្តាប់គួរឲ្យចង់មើលចង់អាន។
- ថេរវេលានៃការសិក្សានេះ មិនមានកំណត់ទេ តែបើសិក្សាឲ្យគម្រប់៣ឆ្នាំទើបសន្មតថា អស់ការសិក្សាមួយលើក។ ក្នុងការអាស្រ័យក្នុងវត្តនេះ សិស្សបានទទួលការអប់រំគ្រប់យ៉ាង។ លោកគ្រូមិនមែនបង្រៀនតែអក្សរ ធម៌អាថ៌ប៉ុណ្ណោះទេ លោកអប់រំធម្មចរិយាទៀត បង្រៀនឲ្យចេះគោរពគ្រូ មាតាបិតា ញាតិការទូទៅ រហូតដល់អ្នកធំ អ្នកតូច ឲ្យចេះសំពះឱនលំទោន ចេះដាក់ខ្លួនឲ្យសម ដឹងខ្ពស់ដឹងទាប ស្គាល់ខុសស្គាល់ត្រូវ ស្គាល់ល្អអាក្រក់ គុណទោស រាក់ជ្រៅ ។ល។ អាស្រ័យដោយការអប់រំនៅវត្តនេះហើយ បានជាប្រជាជនខ្មែរមានចរិតស្លូតបូត និងសុភាពរាបសា។

## ២.៤.២. ការធ្វើទំនើបកម្មសាលាវត្ត (ពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩០៦)

- ដោយសារសាលារៀនបារាំង-ខ្មែរ មិនទាន់មានលទ្ធភាពរីកសាយភាយដល់ជនបទស្រុកភូមិទូទាំងប្រទេស ប្រជាជនខ្មែរនៅតែបញ្ជូនកូនចៅឱ្យទៅសិក្សានៅតាមវត្តដដែល តែសាលាវត្តនេះមានលក្ខណៈខុសពីមុន ដោយត្រូវបានបារាំងបំពាក់នូវគរុកោសល្យថ្មីបែបបស្ចិមប្រទេសបន្ថែមលើការសិក្សាតាមផ្លូវព្រះធម៌។ សាលាវត្តបែបថ្មី ក្នុងគ្រាដំបូងមិនទាន់ទទួលបានការពេញនិយមភ្លាមៗនោះទេ គឺមានន័យថាការចាប់ផ្តើមថ្មីដែលជាជំហានដំបូងនៃការកែទម្រង់ការសិក្សានេះ មិនទាន់បានទទួលជោគជ័យភ្លាមៗនោះទេ។

### ២.៤.២. ការធ្វើទំនើបកម្មសាលាវត្ត (ពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩០៦)

## ក. ការវិវត្តរបស់សាលាវត្ត

- ក្រុមប្រឹក្សានៃការសិក្សាបានដាក់ចេញគោលការណ៍នៅឆ្នាំ១៩០៦ថា "សាលាវត្ត គឺជាមូលដ្ឋានធំនៃការចាត់ចែងផ្នែកសិក្សាធិការ" ហើយដំណើរការនៃការកែប្រែសាលាវត្តត្រូវបានធ្វើឡើងនៅឆ្នាំ១៩០៨ (ឃឹន សុខ ២០០៣:៤៩)។
- នៅក្នុងឆ្នាំ១៩០៨ រេស៊ីដង់បារាំងប្រចាំខេត្តកំពង់ចាមម្នាក់ឈ្មោះលោក បូឌ័ង ព្រមទាំងសហការីរបស់លោកឈ្មោះ មេណោទ្រីយេ បានយកវត្តមួយនៅខេត្តនោះមកបណ្តុះបណ្តាលវិធីសាស្ត្រថ្មីដល់គ្រូដែលជាព្រះសង្ឃ។ ការសិក្សាអប់រំនៅជំហានដំបូង មិនបានទទួលជោគជ័យទេ ធ្វើឱ្យបារាំងមិនសប្បាយចិត្ត ហើយថែមទាំងបន្ទោសដល់ព្រះសង្ឃដែលជាគ្រូអាចារ្យទៀតផង។ (ជា សោភារី និង ហ៊ុយ ស៊ីវង ២០០៧:២៣)។

- នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩១២ មានព្រះរាជបញ្ញត្តិមួយកំណត់ចំពោះឪពុកម្តាយ គឺត្រូវតែបញ្ជូនកូនចៅឱ្យទៅរៀននៅសាលាវត្ត។ បើ "ឪពុកម្តាយដែលមិនបញ្ជូនកូនទៅរៀននៅសាលាវត្តដោយពុំមានមូលហេតុត្រឹមត្រូវ គឺត្រូវជាប់ពិន័យជាប្រាក់១ព្យ៉ាស (១រៀល) នៅលើកទី១ ហើយប្រាក់ពិន័យនេះ នឹងត្រូវឡើងទៅជា២ព្យ៉ាស បើនៅតែមិនព្រមធ្វើតាមព្រះរាជបញ្ញត្តិ" (ឃឹន សុខ ២០០៣:៥១)។ ក្រោយមកក៏មានសារាចរមួយឱ្យអភិបាលខេត្តចេញទៅផ្សព្វផ្សាយជំរុញបន្ថែមស្តីពីការសិក្សានេះ។ កាលណាឪពុកម្តាយនៅតែមិនព្រមបញ្ជូនកូនឱ្យទៅរៀនទៀត នោះគេត្រូវយកព្រះរាជបញ្ញត្តិមកអនុវត្ត។
- ដោយសារបរាជ័យនេះហើយ បារាំងបង្កើតសាលាមួយដែលអាចជួយបំពេញនូវកង្វះខាតនេះបាន។ សាលាអនុវត្តន៍ទី១ ត្រូវបានបង្កើតឡើងនៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩២៤ នៅខេត្តកំពត។ គេបាននិមន្តព្រះសង្ឃដែលត្រូវមាននាទីបង្រៀនឱ្យទៅរៀនវិធីសាស្ត្រគំរូនានា ដើម្បីយកទៅបង្រៀនបន្តដល់សិស្សានុសិស្សដែលចូលរៀននៅសាលាវត្តបែបថ្មី។ វគ្គសិក្សានេះមានរយៈពេល៩ខែ ហើយនៅក្នុងរយៈពេល៩ខែនោះ ព្រះសង្ឃត្រូវរៀនតាមកម្មវិធីដូចជា រៀនធ្វើសំបុត្រផ្សេងៗ រៀនអាន គិតលេខ និងប្រើប្រាស់រង្វាស់រង្វាល់ រៀនប្រវត្តិសាស្ត្រកម្ពុជា ព្រមទាំងរៀនអំពីវិធីបង្ការរោគនានា(ឃឹន សុខ ២០០៣:៥២)។

- នៅក្នុងខេត្តកំពត សាលាវត្តបែបទំនើបនេះបានកើនចំនួនបន្តិចម្តងៗ និងបានទទួលការពេញនិយមពីសំណាក់ព្រះសង្ឃ និងប្រជាជនខ្មែរជាងមុន។ ជាក់ស្តែងនៅឆ្នាំ១៩២៤ មានសាលាវត្តបែបនេះតែ១ប៉ុណ្ណោះ តែដល់ឆ្នាំ១៩៣០ សាលាបែបនេះក៏កើនរហូតដល់ទៅ៥៨កន្លែង ហើយចាប់ពីឆ្នាំ១៩៣០ បារាំងក៏បានយកបទពិសោធពីសាលាអនុវត្តន៍នៅខេត្តកំពតនេះ ទៅអនុវត្តនៅទូទាំងប្រទេស។ **សូមពិនិត្យមើលចំនួនសាលា និងចំនួនសិស្សដែលកើនឡើងជាបន្តបន្ទាប់នៅក្នុងតារាងខាងក្រោមក្នុងស្លាយបន្ទាប់** (ខ្លូត ធីតា ២០០៥:១២០)។
- នៅពេលដំបូង ការបណ្តុះបណ្តាលមិនទាន់ទទួលបានជោគជ័យទេ ដោយសារគ្រូខ្វះខាតគរុកោសល្យក្នុងការបង្រៀន ហើយបារាំងចង់ឱ្យកុមារីបានចូលរៀនដែរ ក៏ប៉ុន្តែទង្វើនេះវាខុសពីប្រពៃណីខ្មែរដែលមិនអនុញ្ញាតឱ្យក្មេងស្រីចូលរៀននៅសាលាវត្ត។ អាស្រ័យហេតុនេះហើយ ទើបការកែទម្រង់ថ្មីរបស់បារាំងមិនសូវជាទទួលបានផលភ្លាមៗនោះទេ ព្រោះគេពុំសូវឃើញក្មេងទៅរៀនតាមប្រព័ន្ធសិក្សាបែបថ្មីនោះឡើយ។ ជាក់ស្តែងរហូតដល់ឆ្នាំ១៩៣៦ គេឃើញមានសិស្សស្រីត្រឹមតែ១២១នាក់ប៉ុណ្ណោះ ដែលបានទៅចូលរៀននៅសាលាវត្តនៅទូទាំងប្រទេស។

# ការរីកចម្រើននៃសាលាវត្តបែបថ្មីក្នុងខេត្តកំពត (១៩២៤-១៩៣០)

| ឆ្នាំសិក្សា | ចំនួនសាលា | ចំនួនសិស្ស |
|---|---|---|
| ១៩២៤ | ១ | ៥៣ |
| ១៩២៥ | ៥ | ២១០ |
| ១៩២៦ | ១០ | ៤៦៥ |
| ១៩២៧ | ១០ | ៤៦៥ |
| ១៩២៨ | ២០ | ១.០៧៧ |
| ១៩២៩ | ២៥ | ១.២១៦ |
| ១៩៣០ | ៥៨ | ២.៧៧៥ |

## ខ. ការសិក្សានៅសាលាវត្ត

- ដើម្បីធ្វើឱ្យការគ្រប់គ្រងសាលាវត្តទាំងនេះមានភាពងាយស្រួល បារាំងបានបង្កើតនូវរចនាសម្ព័ន្ធមួយចំនួន មានដូចជាអគ្គាធិការដ្ឋាន (អធិការធំ) ទូទាំងប្រទេសដែលមានទីតាំងនៅរាជធានី អធិការដ្ឋានប្រចាំខេត្តនីមួយៗ ព្រមទាំងអធិការដ្ឋានប្រចាំស្រុកនីមួយៗទៀតផង។ ក្រសួងសិក្សាធិការចាត់ឱ្យផ្នែកគរុកោសល្យជាអ្នកទទួលបន្ទុករៀបរៀងសៀវភៅកម្មវិធីសិក្សាផ្ញើទៅគ្រប់វត្ត ហើយលោកគ្រូបង្រៀនមាននាទីបែងចែកកម្មវិធីនេះដោយខ្លួនឯង (មៀច ប៉ុណ្ណ ២០០៧:៤៥)។ សម្រាប់កុមារកម្រិតបឋមសិក្សា ការសិក្សាមានរយៈពេលបីឆ្នាំ ហើយភាសាដែលប្រើក្នុងការបង្រៀនគឺភាសាខ្មែរ។ លោកមៀច ប៉ុណ្ណ ក៏បានលើកឡើងទៀតថា សិស្សត្រូវបានបែងចែកជាបីកម្រិតគឺថ្នាក់កុមារដ្ឋាន (សម្រាប់កុមារដែលមិនទាន់ចេះ) ថ្នាក់បរិវច្ឆនដ្ឋាន (ថ្នាក់ត្រៀម) និងថ្នាក់បដិញ្ញាណដ្ឋាន (ពេលបញ្ចប់ថ្នាក់នេះ សិស្សអាចប្រឡងយកសញ្ញាបត្របឋមសិក្សាជាន់ដំបូងបាន)។ ពួកគេត្រូវរៀននៅពេលរសៀលពីម៉ោង៣កន្លះដល់ម៉ោង៦កន្លះ លើកលែងតែថ្ងៃសីលដែលមានបួនដងក្នុងមួយខែ។ **បន្ទាប់ពីបានសិក្សា សិស្សអាចមានជម្រើសបីយ៉ាងគឺ៖** ទីមួយសិស្សអាចបន្តការសិក្សានៅសាលារដ្ឋ ហើយសិស្សដែលបានប្រឡងជាប់សញ្ញាបត្របឋមសិក្សាជាន់ដំបូង ត្រូវរៀនត្រឹមថ្នាក់បរិវេច្ឆនដ្ឋានក្នុងសាលាបារាំង ព្រោះកម្មវិធីសិក្សាភាសាបារាំងរៀនចាប់ពីថ្នាក់នេះទៅ ទីពីរសិស្សអាចចូលបួសរៀនជាសាមណេរក្នុងវត្តដែលខ្លួនបានរៀន និង ទីបី សិស្សអាចផ្អាកការសិក្សានៅត្រឹមនេះ ហើយវិលមកប្រកបការងារស្រែចម្ការជាមួយឪពុកម្តាយរបស់ខ្លួនវិញបាន។

## ២.៤.៣. ការបង្កើតប្រព័ន្ធអប់រំផ្លូវការនៅកម្ពុជា (ពីឆ្នាំ១៩០៦ ដល់ឆ្នាំ១៩៥៣)

### ក. សាលាបឋមសិក្សាបារាំង-ខ្មែរ

- ប្រព័ន្ធអប់រំផ្លូវការត្រូវបានបង្កើតឡើងនៅដើមសតវត្សរ៍ទី២០ក្នុងនោះមានអនុវិទ្យាល័យព្រះស៊ីសុវត្ថិ(១៩៣៥) ក្រោយមកទៅជាវិទ្យាល័យព្រះស៊ីសុវត្ថិ និងសាលាបារាំង-ខ្មែរចំនួនបីទៀតនៅខេត្តកំពត តាកែវ និងកំពង់ចាម។ សាលាទំនើបដែលចម្លងកម្មវិធីសិក្សាតាមបារាំងនេះ បានកើតឡើងជាបន្តបន្ទាប់នៅក្រុងភ្នំពេញ និងនៅតាមបណ្ដាខេត្តនានា។
- ចាប់ពីទសវត្សឆ្នាំ១៩០០ ការសិក្សាទំនើបបានចាប់ផ្ដើម ដោយគេបានបង្កើតសាលាបឋមសិក្សាបារាំងនៅតាមឃុំ និងកែប្រែសាលាវត្តឱ្យបង្រៀនតាមបែបទំនើប។ បារាំងបានជួយផ្ដួងផ្ដើមផ្ដល់ថវិកាឱ្យខ្មែរក្នុងការស្ថាបនាសាលារៀន។ សាលារៀនដែលគេស្ថាបនានោះមាន២ផ្នែក គឺមួយជាសាលារៀនក្រៅវត្ត ហៅថាសាលារាជការ ហើយសាលានេះសម្រាប់តែកូននាម៉ឺន និងកូនអ្នកមាននៅតាមទីក្រុង ទើបអាចចូលរៀនបាន។ ឯកូនអ្នកក្រវិញ អាចចូលរៀនបាននៅសាលាវត្ត (សៅ ឆាត ១៩៩៣:២៧)។
- ក្នុងឆ្នាំ១៩១៨ អគ្គទេសាភិបាលAlbert Sarraut បានដាក់ឱ្យអនុវត្តប្រព័ន្ធអប់រំចំនួន១៣ឆ្នាំ (បឋមសិក្សា៦ឆ្នាំ មធ្យមសិក្សាបឋមភូមិ៤ឆ្នាំ និងមធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ) នៅទូទាំងឥណ្ឌូចិនដើម្បីឱ្យសមមូលជាមួយប្រព័ន្ធអប់រំបារាំង។

- ចំណែកប្រព័ន្ធបណ្ដុះបណ្ដាលគ្រូត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩២២ នៅក្នុងអនុវិទ្យាល័យព្រះស៊ីសុវត្ថិផ្នែកគរុវិជ្ជា ដោយគ្រូនិងនាយកសាលាត្រូវសិក្សាចំនួន៤ឆ្នាំ ហើយចាប់ដំណើរការពីបវេសនកាល១៩២៣-១៩២៤ (ឆ្នាំទី១) ដោយមានគរុសិស្ស៣៦នាក់ និងចុះកិច្ចសន្យាបង្រៀនរយៈពេល១០ឆ្នាំ បន្ទាប់ពីចេញធ្វើគ្រូ។
- ឆ្នាំ១៩២១ មានតែសាលាចំនួន១៤ ប៉ុណ្ណោះជាសាលាបឋមសិក្សាបំពេញវិជ្ជា ដែលសិស្សរៀនចំនួន៦ឆ្នាំ មានសិស្សចំនួន៣ ៣៤៥នាក់ និងមានសាលាបឋមសិក្សាជាន់ដំបូងចំនួន៤៣ មានសិស្សចូលរៀនចំនួន១ ៦៣៨ (និងមានប្រជាជនប្រមាណ២,៥លាននាក់)។ មួយទសវត្សរ៍ក្រោយមកគឺក្នុងឆ្នាំ១៩៣១ ចំនួនសាលារដ្ឋបារាំង-ខ្មែរពេញលេញ(សាលាបឋមសិក្សាបំពេញវិជ្ជា) បានកើនឡើងត្រឹមចំនួន១៨ និងមានសិស្សចំនួន៥ ៨៣៨នាក់ និងមានសាលាបឋមសិក្សាជាន់ដំបូងចំនួន៩៣ ដែលមានសិស្សចំនួន៤ ៨៥៣។

- មូលហេតុដែលធ្វើឱ្យសិស្សរៀននៅសាលារដ្ឋមានចំនួនតិច គឺដោយសារៈ (១) ក្មេងស្រីមិនត្រូវបានលើកទឹកចិត្តឱ្យទៅរៀនសាលាវត្ត (២) កង្វះខាតគ្រូបង្រៀនដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ (៣) កង្វះខាតសៀវភៅសិក្សាគោលជាខេមរភាសា (៤) ប្រជាជនភាគច្រើនមិនចេះអក្សរ និងមិនយល់ពីតម្លៃនៃការសិក្សា (៥) កម្មវិធីសិក្សាមិនបានផ្តោតទៅលើបរិស្ថានជុំវិញសាលា ជាហេតុធ្វើឱ្យការសិក្សាមិនសូវមានប្រយោជន៍ក្នុងជីវភាពរស់នៅ (៦) ការចូលរៀនក្នុងសាលាបឋមសិក្សាបំពេញវិជ្ជាត្រូវមានអាហារូបករណ៍ និង(៧) ប្រជាជនគ្មានធនធានដើម្បីបញ្ជូនកូនទៅរៀនក្នុងសាលារដ្ឋ។

- ការសិក្សាសម័យនោះ សម្តៅទៅលើការរៀនអក្សរ រៀនលេខនព្វន្ត សូត្រកំណាព្យ ស្មូត្រ និងធម៌អាថ៌។ បើប្រុសៗ គេរៀនអារ ចាំង ឈូស ដាប់ឈើ ធ្វើផ្ទះ តុ ទូ ទូក ក្តារដ្ឋ កឿង ត្បាញកញ្ជើ ល្អី កញ្ច្រែងៗល។ ឯស្រីវិញ រៀនរវៃសូត្រ អំបោះ ត្បាញ ធ្វើគោម ចង្កៀង ទៀន ធូបៗល។
- នៅភ្នំពេញក្នុងឆ្នាំ១៩០៣ ស្តេចនរោត្តមបានបើកសាលាត្រៀមមួយឈ្មោះសាលានរោត្តម សម្រាប់បុត្រធីតា និងកូនរាជការ។ រីឯនៅតាមបណ្តាខេត្តវិញ សាលាបឋមសិក្សាបារាំង-ខ្មែរ២ទៀត បានបើកទ្វារឡើងគឺមួយនៅខេត្តកំពង់ចាម ហើយមួយទៀតនៅខេត្តពោធិ៍សាត់ (ឃើង ហុកឌី ២០០៧:១៧)។
- នៅឆ្នាំ១៩០៤ នៅរាជធានីភ្នំពេញមានវិទ្យាល័យ ៉ស៊ីសុវត្ថិ៉ តែមួយគត់ដែលត្រូវបានបង្កើត។ នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩១៥ ព្រះបាទស៊ីសុវត្ថិ បានបង្កើតគណៈកម្មការមួយដែលមានតួនាទីរៀបចំវចនានុក្រមខ្មែរជាលើកដំបូង ហើយនៅឆ្នាំ១៩២១ ទ្រង់បានបញ្ជាឱ្យកសាងសាលាបាលីជាន់ខ្ពស់ និងរាជបណ្ណាល័យបន្ថែមទៀត។

- សាលាឯកជនក៏ត្រូវបានបង្កើតឡើងនាពេលនោះដែរ គឺមានដូចជាសាលាម៉ាលីកា (ដែលត្រូវបានបង្កើតឡើងដោយព្រះអង្គម្ចាស់ម៉ាលីកា) និងសាលាសុធារស (សម្រាប់កូនអ្នកមាននៅទីក្រុង)។ នៅឆ្នាំ១៩១៩ គេក៏បានបង្កើតសាលាសម្រាប់នារីមួយទៀតដែល ឈ្មោះថា សាលាដូដាជីឡាប្រេ្គ (ដា សោភារី និងហ៊ុយ ស៊ីវង ២០០៧: ៤៣)។
- នៅទសវត្សរ៍ក្រោយៗទៀត សាលាបឋមសិក្សានៅទូទាំងប្រទេសបានកើនចំនួនច្រើនជាងមុន រីឯចំនួនសិស្សក៏បានកើនឡើងទៅតាមនោះផងដែរ។
- នៅឆ្នាំ១៩២១ ខ្មែរយើងមានសាលាបឋមសិក្សាប្រហែល៣០ខ្នង ហើយនៅឆ្នាំ១៩៣៧ សាលាបឋមសិក្សាមានចំនួនរហូតដល់៨១៣ខ្នង ដោយមានសិស្សានុសិស្សដល់ទៅ៣៤ពាន់នាក់ (ឃ.ឃ.មីហេយេរ ១៩៩៩:២៦)។
- ភាសាដែលគេប្រើនៅក្នុងសាលាបឋមសិក្សាបារាំង-ខ្មែរនេះ គឺនៅឆ្នាំដំបូងគេបង្រៀនដោយប្រើភាសាខ្មែរ ហើយភាសាបារាំងត្រូវបានគេប្រើនៅឆ្នាំទី២ និងឆ្នាំបន្តបន្ទាប់ លើកលែងតែមេរៀនសីលធម៌ និងមេរៀនភាសាខ្មែរ ដែលត្រូវរៀនជាភាសាខ្មែរ (Bilodeau, Pathammavong & Hong, ១៩៥៥:២៣)។

# សាលាវត្តបែបថ្មីនៅទូទាំងប្រទេស

| ឆ្នាំសិក្សា | ចំនួនសាលា | ចំនួនសិស្សសរុប | សិស្សស្រី |
|---|---|---|---|
| ១៩៣៥-១៩៣៦ | ៨១៣ | ៣៤.៥៨៣ | ១២១ |
| ១៩៣៧-១៩៣៨ | ៨៩៥ | ៣៨.០១៧ | ១០៦ |
| ១៩៣៩-១៩៤០ | ១០០៦ | ៤៣.៨២៥ | ៩៤ |
| ១៩៤១-១៩៤២ | ៨៦០ | ៣៧.០៩៦ | ...... |
| ១៩៤៣-១៩៤៤ | ១០២៨ | ៤៩.៥១៥ | ២៥០ |
| ១៩៤៥-១៩៤៦ | ១១១០ | ៥២.៩៤៦ | ១២០ |
| ១៩៤៧-១៩៤៨ | ១៣៨៧ | ៦១.៧៩៨ | ...... |
| ១៩៤៩-១៩៥០ | ១៤៤១ | ៦៧.៤៥៩ | ...... |
| ១៩៥២-១៩៥៣ | ១៤៣១ | ៧៦.៣០៧ | ...... |

## ខ. សាលាមធ្យមសិក្សា

- សាលាបឋមសិក្សាជាន់ខ្ពស់ដែលមានឈ្មោះថាអនុវិទ្យាល័យអាណាព្យាបាលបារាំង ត្រូវបានបង្កើតក្នុងឆ្នាំ១៨៩៣។ សាលានេះមានសិស្សត្រឹមតែ៦៥នាក់ប៉ុណ្ណោះនៅឆ្នាំ១៩០៧។ នៅឆ្នាំ១៩១១ អនុវិទ្យាល័យនេះ ត្រូវបានដូរឈ្មោះទៅជាអនុវិទ្យាល័យស៊ីសុវត្ថិវិញ។ នៅឆ្នាំ១៩២០ អនុវិទ្យាល័យនេះមានសិស្សចំនួន១២៩នាក់។ ក្រោយមក សាលានេះត្រូវបានចែកចេញជាពីរផ្នែក៖ សាលាបឋមសិក្សាជាន់ខ្ពស់ និងសាលាមធ្យមសិក្សា ហើយនៅឆ្នាំ១៩២២ គេបានបង្កើតផ្នែក "គរុវិជ្ជា" សម្រាប់បណ្តុះបណ្តាលសិស្សឱ្យទៅជាគ្រូបង្រៀន (ឃីន សុខ ២០០៣:៥០)។
- នៅមុនឆ្នាំ១៩៣៦ សិស្សដែលបានប្រឡងជាប់អនុវិទ្យាល័យស៊ីសុវត្ថិ ត្រូវបញ្ឈប់ការសិក្សា ព្រោះមិនទាន់មានវិទ្យាល័យ (ដេវិឌ ឆាណ្ឌល័រ ២០០៥:១៧៣)ប៉ុន្តែសិស្សមានលទ្ធភាព អាចបន្តការសិក្សានៅទីក្រុងព្រៃនគរ។
- ប្រទេសកម្ពុជាមានវិទ្យាល័យរបស់ខ្លួនដែលមានឈ្មោះថាវិទ្យាល័យព្រះស៊ីសុវត្ថិនៅក្នុងឆ្នាំ១៩៣៦ (ដេវិឌ ឆាណ្ឌល័រ ២០០៩:១៨៨)។ រហូតមកដល់ឆ្នាំ១៩៣៩ ចំនួនសិស្សដែលបានប្រឡងជាប់មធ្យមសិក្សាបត្រភាគទី២ (បាក់ឌុប) ចេញពីវិទ្យាល័យព្រះស៊ីសុវត្ថិ មានចំនួនតែ៦នាក់ប៉ុណ្ណោះ (ដេវិឌ ឆាណ្ឌល័រ ២០០៩:១៩៣)។ នៅក្នុងការបណ្តុះបណ្តាលកម្រិតមធ្យមសិក្សាគឺត្រូវបង្រៀនជាភាសាបារាំង ហើយគ្រូដែលមកបង្រៀនមួយចំនួនធំក៏ជាជនជាតិបារាំងដែរ (Bilodeau, Pathammavong & Hong, ១៩៥៥:២៤)។

## គ. កម្រិតឧត្តមសិក្សា

- នៅមុនឆ្នាំ១៩៤៨ មាននិស្សិតខ្មែរតិចណាស់ដែលមានសំណាងបានរៀនដល់កម្រិតឧត្តមសិក្សា។
- សិស្សដែលបានបញ្ចប់ការសិក្សានៅវិទ្យាល័យស៊ីសុវត្ថិ ត្រូវបន្តទៅសិក្សានៅបរទេស។ ប៉ុន្តែបើតាមលោក ដាវិឌ ឆាណ្ឌលែរ (២០០៩:១៩៣) មាននិស្សិតខ្មែរចំនួនប្រហែលជា១២នាក់ប៉ុណ្ណោះ ដែលបានចេញទៅបន្តការសិក្សានៅសាកលវិទ្យាល័យនៅក្រៅប្រទេស។
- យោងតាមលោក ឃឹន សុខ (២០០៣:៥០) គ្រឹះស្ថានឧត្តមសិក្សាដំបូងបំផុត បានកើតឡើងនៅឆ្នាំ១៩៤៨ ដូចជាវិទ្យាស្ថានជាតិ ខាងច្បាប់ នយោបាយ និងសេដ្ឋកិច្ច ព្រមទាំងសាលាភូមិន្ទពេទ្យ។

# ប្រព័ន្ធអប់រំ៖ ១៣ឆ្នាំ (៣+៣+៤+៣)

| បឋមសិក្សា ៦ឆ្នាំ | កម្រិតសិក្សា ឬភូមិសិក្សា៖ | ការប្រឡងបញ្ចប់ |
|---|---|---|
| ១.បឋមភូមិដាន់ដំបូង បារាំង-ខ្មែរ (៣ឆ្នាំ) | កុមារដ្ឋាន បរិវច្ឆណដ្ឋាន និងអាទិកដ្ឋាន | ប្រឡងបញ្ចប់យកវិញ្ញាបនបត្របឋមភូមិដាន់ដំបូង (Certificat d´Etudes Elementaires) |
| ២.បឋមភូមិបំពេញវិជ្ជា បារាំង-ខ្មែរ (៣ឆ្នាំ) | មជ្ឈឹមដ្ឋានទី១ មជ្ឈឹមដ្ឋានទី២ និងឧត្តមដ្ឋាន | ប្រឡងបញ្ចប់យកវិញ្ញាបនបត្របឋមភូមិបំពេញវិជ្ជា (Certificat d´Etudes Primaires Comple´mentaires ) |
| **មធ្យមសិក្សា ៧ឆ្នាំ** | **កម្រិតសិក្សា ឬភូមិសិក្សា៖** | **ការប្រឡងបញ្ចប់** |
| ១. មធ្យមសិក្សាបឋមភូមិ (៤ឆ្នាំ) | ថ្នាក់ទី៦ទំនើបជាតិ ថ្នាក់ទី៥ទំនើបជាតិ ថ្នាក់ទី៤ទំនើបជាតិ និងថ្នាក់ទី៣ទំនើបជាតិ | ប្រឡងចំនួន២លើក «សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ » |
| ២. មធ្យមសិក្សាទុតិយភូមិ (៣ឆ្នាំ) | ថ្នាក់ទី២ទំនើបជាតិ ថ្នាក់ទី១ទំនើបជាតិ និងថ្នាក់បញ្ចប់ | ប្រឡងចំនួន២លើក «សញ្ញាបត្រសាលកបត្រភាគI ចប់ថ្នាក់ទី១ (បាក់អង) និងសាលកបត្រភាគII ថ្នាក់ទីបញ្ចប់» (បាក់ឌុប) |

- នៅថ្នាក់ទីបញ្ចប់គេរៀន៣បណ្តុំមុខវិជ្ជា៖ ទស្សនវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្ត្រពិសោធន៍។ ការប្រឡងគេអាចប្រឡងសាលកបត្រភាគII តាមបណ្តុំ។ ចំណែកវិធីសាស្ត្របង្រៀនវិញ គេប្រើប្រាស់កម្មវិធីសិក្សា និងគរុកោសល្យបែបបារាំង។
- ឆ្នាំ១៩៤២ មហាវិទ្យាល័យគរុកោសល្យ ត្រូវបានបង្កើតឡើងដាច់ដោយឡែកពីវិទ្យាល័យស៊ីសុវត្ថិ ការបណ្តុះបណ្តាលរយៈពេល៥ឆ្នាំ ដោយនៅដំណាច់ឆ្នាំ គរុសិស្សត្រូវប្រឡងយកប្រកាសនីយបត្រគរុកោសល្យសម្បទា។ ប្រសិនបើគរុសិស្សណាធ្លាក់មិនបានប្រកាសនីយបត្រនោះទេ នឹងត្រូវតែងតាំងត្រឹមជាគ្រូជំនួយ។

# សង្ខេបការអប់រំពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣

## ប្រព័ន្ធអប់រំយកតាមគំរូប្រទេសបារាំង (6+4+2+1)

- ✓ ក្នុងអំឡុងពេលប្រទេសកម្ពុជាស្ថិតជាប្រទេសក្រោមអាណាព្យាបាលបារាំង និងក្រោយមកជាប្រទេសស្ថិតនៅក្រោមអាណានិគមបារាំង ប្រព័ន្ធអប់រំនៃប្រទេសនេះ ពឹងផ្អែកទាំងស្រុងទៅលើប្រព័ន្ធអប់រំរបស់ប្រទេសបារាំង ប៉ុន្តែការអប់រំតាមបែបប្រពៃណីក៏នៅតែបន្តអនុវត្ត។
- ✓ ការអប់រំនៅកម្រិតបឋមសិក្សា ត្រូវបានបែងចែកជា២វគ្គ ហើយក្នុង១វគ្គៗមានរយៈពេល៣ឆ្នាំ។ ខេមរៈយាន ឬខេមរៈភាសា ត្រូវបានគេប្រើប្រាស់នៅវគ្គដំបូង និងភាសាបារាំងត្រូវបានប្រើប្រាស់នៅវគ្គបន្ទាប់ក្នុងកម្រិតបឋមសិក្សានេះ។
- ✓ ការអប់រំនៅកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ ត្រូវបានបែងចែកជា២វគ្គដែរ៖ កម្រិតអនុវិទ្យាល័យ ឬហៅថា College មានរយៈពេលសិក្សា៤ឆ្នាំ និងកម្រិតវិទ្យាល័យ ឬហៅថា Lycée មានរយៈពេល៣ឆ្នាំ។ ចំណែកកម្មវិធីសិក្សា គឺដូចគ្នាបេះបិទទៅនឹងកម្មវិធីសិក្សាចំណេះទូទៅនៅប្រទេសបារាំង។

## The French Model (6+4+2+1)

- ➢ During the period of the French protectorate, an educational system based on the French model was inaugurated alongside the traditional system.
- ➢ Primary education was divided into 2 cycles of 3 years each. Khmer was the language of instruction in the 1st cycle, and French was used in the 2nd cycle and thereafter.
- ➢ Secondary education was also divided into two cycles: one of 4 years taught at a college, followed by one of 3 years taught at a lycée. The Cambodian secondary curriculum was similar to that found in France.

## ២.៥. ការអប់រំនៅក្នុងសម័យសង្គមរាស្ត្រនិយម (១៩៥៣ ដល់ឆ្នាំ១៩៧០)

- បន្ទាប់បានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ វិស័យអប់រំបានក្លាយទៅជាវិស័យអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការកសាងប្រទេសជាតិក្រោមការដឹកនាំរបស់ព្រះបាទ**សម្តេចព្រះនរោត្តម សីហនុ**។ ថវិកាជាតិប្រមាណជា២០% ចំណាយលើវិស័យអប់រំ។ គ្រូបង្រៀនត្រូវបានចាត់ទុកថាជាវិជ្ជាជីវៈដែលមានកិត្យានុភាពខ្ពស់ជាងគេបំផុតនៅក្នុងសង្គមកម្ពុជានាសម័យនោះ (ការគោរព ប្រាក់បៀវត្សខ្ពស់ និងការគាំទ្រផ្សេងៗពីអាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នជាតិ)។
- សាលារៀនជាច្រើនត្រូវបានចាត់ទុកថាជាថ្នាលបណ្តុះបញ្ញា ស្មារតី គំនិតស្នេហាជាតិ និងជាទីកន្លែងសម្រាប់អនុវត្ត កម្មវិធីសិក្សាជាតិ ហើយការប្រឡងថ្នាក់ជាតិគឺត្រូវបានចាត់ទុកជារបាំងមួយដើម្បីជ្រើសសិស្សឆ្នើមបំផុតដើម្បីឱ្យពួកគេបន្តការសិក្សាទៅមុខទៀត។

## ២.៥. ការអប់រំនៅក្នុងសម័យសង្គមរាស្រ្តនិយម (១៩៥៣ ដល់ឆ្នាំ១៩៧០) (ត)

- ក្រសួងអប់រំជាតិ បានបង្កើតគណៈកម្មការបច្ចេកទេសដើម្បីរៀបចំសៀវភៅគោលសិក្សាតាមមុខវិជ្ជាខាងផ្នែកពាក្យ វេយ្យាករណ៍ អក្សរសាស្រ្ត ប្រវត្តិវិទ្យា ភូមិវិទ្យា ទស្សនវិជ្ជា សិល្បៈ គណិតវិទ្យា រូបវិទ្យា គីមី ធម្មជាតិវិទ្យា រោងជាង កសិកម្ម កីឡា និងវិជ្ជាមេផ្ទះ។
- មុនឆ្នាំ១៩៥០ កម្ពុជាគ្មានគ្រឹះស្ថានឧត្តមសិក្សាទេ។ នៅឆ្នាំ១៩៥៥ កម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាពីរ៖ សាកលវិទ្យាល័យភ្នំពេញ និងឧត្តមសិក្សាបច្ចេកទេសខាងវិជ្ជាជីវៈនិងខាងសិល្បៈ ដែលមាននិស្សិតសរុបចំនួន៣៥០នាក់។ ជាងដប់ឆ្នាំក្រោយមកក្នុងឆ្នាំ១៩៦៦ កម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាចំនួន៣៧ និងមាននិស្សិតចំនួន៧៣៦០នាក់។

# ចំនួនសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ

| ឆ្នាំសិក្សា | សិស្សមកប្រឡង | សិស្សប្រឡងជាប់ | ភាគរយ | សង្កេត |
|---|---|---|---|---|
| 1960/61 | 6 276 | 1 474 | 23,48% | ការសិក្សាជាភាសាបារាំងពីឆ្នាំ១៩៦០ |
| 1961/62 | 9 333 | 2 160 | 23,14% | ដល់ឆ្នាំ ១៩៦៩ |
| 1962/63 | 12 348 | 3 458 | 28,00% | |
| 1963/64 | 15 325 | 3 727 | 24,31% | |
| 1964/65 | 16 320 | 5 643 | 34,57% | |
| 1965/66 | 18 251 | 7 716 | 42,27% | |
| 1966/67 | 18 810 | 5 893 | 31,32% | |
| 1967/68 | 22 150 | 6 561 | 29,63% | |
| 1968/69 | 23 004 | 8 794 | 38,22% | ការសិក្សាជាខេមរភាសាពីឆ្នាំ១៩៧០ |
| 1969/70 | 21 468 | 18 700 | 87,10% | |
| 1970/71 | 13 438 | 7 407 | 55,11% | |
| | 4 636 (អ្នករៀនជាភាសាបារាំង) | 1 165 | 25,12% | |

ប្រភព៖ ក្រសួងអប់រំជាតិ «ស្ថានភាពខេមរយានកម្មនៅមធ្យមសិក្សា ឆ្នាំ១៩៧២» វិទ្យាស្ថានជាតិខេមរយានកម្ម ឆ្នាំ១៩៧២

## ប្រព័ន្ធអប់រំ៖ ១៣ឆ្នាំ (៣+៣+៤+៣)

| បឋមសិក្សា ៦ឆ្នាំ | កម្រិតសិក្សា ឬភូមិសិក្សា៖ | ការប្រឡងបញ្ចប់ |
|---|---|---|
| ១.បឋមភូមិដាន់ដំបូង បារាំង-ខ្មែរ (៣ឆ្នាំ) | ថ្នាក់ទី១២ ទី១១ ទី១០ | ប្រឡងបញ្ចប់យកវិញ្ញាបនបត្របឋមភូមិដាន់ដំបូង (Certificat d´Etudes Elementaires) |
| ២.បឋមភូមិបំពេញវិជ្ជា បារាំង-ខ្មែរ (៣ឆ្នាំ) | ថ្នាក់ទី៩ ទី៨ ទី៧ | ប្រឡងបញ្ចប់យកវិញ្ញាបនបត្របឋមភូមិបំពេញវិជ្ជា (Certificat d´Etudes Primaires Comple´mentaires) |
| **មធ្យមសិក្សា ៧ឆ្នាំ** | **កម្រិតសិក្សា ឬភូមិសិក្សា៖** | **ការប្រឡងបញ្ចប់** |
| ១. មធ្យមសិក្សាបឋមភូមិ (៤ឆ្នាំ) | ថ្នាក់ទី៦ទំនើបជាតិ ថ្នាក់ទី៥ទំនើបជាតិ ថ្នាក់ទី៤ទំនើបជាតិ និងថ្នាក់ទី៣ទំនើបជាតិ | ប្រឡងចំនួន២លើក «សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ» |
| ២. មធ្យមសិក្សាទុតិយភូមិ (៣ឆ្នាំ) | ថ្នាក់ទី២ទំនើបជាតិ ថ្នាក់ទី១ទំនើបជាតិ និងថ្នាក់បញ្ចប់ | ប្រឡងចំនួន២លើក «សញ្ញាបត្រសាលកបត្រភាគI ចប់ថ្នាក់ទី១ (បាក់អង) និងសាលកបត្រភាគII ថ្នាក់ទីបញ្ចប់» (បាក់ឌុប) |

- នៅថ្នាក់ទីបញ្ចប់គេរៀន៣បណ្តុំមុខវិជ្ជា៖ ទស្សនវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្រ្តពិសោធន៍។ ការប្រឡងគេអាចប្រឡងសាលកបត្រភាគII តាមបណ្តុំ។ ចំណែកវិធីសាស្រ្តបង្រៀនវិញ គេប្រើប្រាស់កម្មវិធីសិក្សា និងគរុកោសល្យបែបបារាំង។
- ឆ្នាំ១៩៤២ មហាវិទ្យាល័យគរុកោសល្យ ត្រូវបានបង្កើតឡើងដាច់ដោយឡែកពីវិទ្យាល័យសីសុវត្ថិ ការបណ្តុះបណ្តាលរយៈពេល៥ឆ្នាំ ដោយនៅដំណាច់ឆ្នាំ គរុសិស្សត្រូវប្រឡងយកប្រកាសនីយបត្រគរុកោសល្យសម្បទា។ ប្រសិនបើគរុសិស្សណាធ្លាក់មិនបានប្រកាសនីយបត្រនោះទេ នឹងត្រូវតែងតាំងត្រឹមជាគ្រូជំនួយ។

- ប្រព័ន្ធអប់រំនៅក្នុងសម័យសង្គមរាស្ត្រនិយម ទទួលបានការកោតសរសើរច្រើន ទាំងការបណ្តុះបណ្តាលគ្រូបង្រៀនទាំងការលើកទឹកចិត្ត ទាំងលក្ខខណ្ឌការងារ ទាំងប្រាក់បៀវត្សរ៍ និងទាំងការគាំទ្រផ្សេងៗទៀត។ រីឯសៀវភៅសិក្សាគោលវិញ ក៏ប្រកបដោយគុណភាព និងសោភ័ណភាពល្អប្រសើរដែរ។ ហេតុដូច្នេះហើយ ទើបការសិក្សាអប់រំនៅសម័យនោះ មានការរីកចម្រើនខ្លាំងគួរឱ្យកត់សម្គាល់។
- ប៉ុន្តែ ការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាបានឈានចូលដល់ទីបញ្ចប់ នៅពេលដែលលោកសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងបានធ្វើឱ្យសង្គ្រាមស៊ីវិលផ្ទុះឡើងនៅក្នុងផ្ទៃប្រទេស។

# សង្ខេបការអប់រំពីឆ្នាំ១៩៥៣-១៩៧០

ប្រព័ន្ធអប់រំយកតាមគំរូរបស់ប្រទេសបារាំង (6+4+2+1)

✓ ថ្វីត្បិតតែកម្ពុជាទទួលបានឯករាជ្យពេញលេញពីបារាំង ក៏ប្រព័ន្ធអប់រំដែលត្រូវបានកំពុងនិងអនុវត្តក្នុងសម័យកាលសម្តេចនរោត្តមសីហនុនោះនៅតែផ្អែកទាំងស្រុងលើប្រព័ន្ធអប់រំរបស់ប្រទេសបារាំងដដែលពោលគឺតាមគំរូ 6+4+2+1។

✓ ប្រព័ន្ធអប់រំ ត្រូវបានបែងចែកជា៖ (១) ការអប់រំបឋមភូមិ (៦ឆ្នាំ) (២) ការអប់រំមធ្យមសិក្សាបឋមភូមិ (៤ឆ្នាំ) (៣) ការអប់រំមធ្យមសិក្សាទុតិយភូមិ ២+១ ដែល ១ឆ្នាំចុងក្រោយគឺការត្រៀមចូលមហាវិទ្យាល័យ (៤) ការអប់រំកម្រិតមហាវិទ្យាល័យ និង (៥) ការអប់រំកម្រិតបច្ចេកទេសឬកម្រិតជំនាញ។

## The French Model (6+4+2+1)

- Although Cambodia gained full independence from France, the system of mass education operated in the period of King Sihanouk was still based on the French model (6+4+2+1).
- The educational system was divided into primary (6), lower secondary (4), upper secondary (2+1 “Faculty preparation”), tertiary, and specialized levels.

## ២.៦. ការអប់រំនៅក្នុងសម័យសាធារណរដ្ឋខ្មែរ (ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥)

- របបសាធារណៈរដ្ឋខ្មែរ ដែលដឹកនាំដោយសេនាប្រមុខលន់ នល់ ហើយរបបនេះប្រសូតចេញមកពីការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ត្រូវបានញាំញីដោយសារភ្នក់ភ្លើងសង្គ្រាមដែលរីករាលដាលទាំងនៅក្រៅទីក្រុងភ្នំពេញ និងនៅទីរួមខេត្តនានានៅទូទាំងប្រទេស ហើយរដ្ឋាភិបាលលោកលន់ នល់ លែងមានឱកាសក្នុងការអភិវឌ្ឍវិស័យអប់រំទៀតហើយ។
- នៅសម័យនោះ គ្រឹះស្ថានសិក្សា មានដូចជាសាកលវិទ្យាល័យ និងសាលារៀននានាស្ទើរតែទាំងអស់ ត្រូវបានបិទទ្វារដោយសារតែបញ្ហាអសន្តិសុខ។ មានតែគ្រឹះស្ថានសិក្សានៅភ្នំពេញប៉ុណ្ណោះដែលបន្តដំណើរការ ប៉ុន្តែមានភាពរអាក់រអួលច្រើនដោយសារភាពរំជើបរំជួលនៃចលនាផ្សេងៗ។

# ការអប់រំ ពីឆ្នាំ១៩៧០-១៩៧៥

## ប្រព័ន្ធអប់រំយកតាមគំរូរបស់ប្រទេសបារាំង

## The French Model ( 6+4+2+1 )

- By the early 1970s, Khmer language was used more widely in primary education, and the English language was also encouraged to study, but the then people were less interested in learning English as they had received long influence from the French language and culture (90 years under the French Colony).

## ២.៧. ការអប់រំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩)

- ប្រព័ន្ធអប់រំនៅកម្ពុជា ត្រូវបានកម្ទេចចោលទាំងស្រុងដោយសារសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ជាងបីទសវត្សរ៍។
- គ្រឹះស្ថានសិក្សាទាំងអស់ ត្រូវបានបិទទ្វារទាំងស្រុងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ហើយការរៀន និងការបង្រៀនត្រូវបានហាមឃាត់។
- អ្នកចេះដឹងដូចជាគ្រូបង្រៀន សាស្ត្រាចារ្យ បញ្ញវន្ត សិស្ស និស្សិត និងមន្ត្រីរាជការពីសង្គមចាស់ គឺជាមុខសញ្ញាដែលត្រូវធ្វើទារុណកម្ម និងសម្លាប់ចោល ឬត្រូវបានស្លាប់ដោយសារអត់អាហារបរិភោគ ធ្វើការហួសកម្លាំង ឬឈឺដោយគ្មានថ្នាំសង្កូវព្យាបាល។

## ២.៧. ការអប់រំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) (ត)

- អគារសិក្សា និងសាលារៀនត្រូវបានបំផ្លាញចោល ឬយកធ្វើជាឃ្លាំង ជារោងបាយ ជាគុក ជាមន្ទីរឃុំឃាំង ឬយកធ្វើជាកន្លែងដាក់ជីកំប៉ុស។ រីឯមន្ទីរពិសោធន៍ បណ្ណាល័យ សៀវភៅសិក្សា និងសម្ភារៈសិក្សាដ៏ទៃទៀត ក៏ត្រូវបានបំផ្លាញចោលដែរ។
- ការអប់រំ មានត្រឹមតែការបង្រៀនឱ្យចេះអានអក្សរ ដើម្បីបំពាក់មនោគមវិជ្ជាបដិវត្តន៍ និងឱ្យស្រឡាញ់អង្គការតែប៉ុណ្ណោះ ដោយចាត់ទុកអង្គការជាម៉ែ ជាឪ។

# ការអប់រំ ពីឆ្នាំ១៩៧៥-១៩៧៩

គ្មានប្រព័ន្ធអប់រំជាផ្លូវការទេ (របបខ្មែរក្រហមនោះ ត្រូវបានពិភពលោកស្គាល់ថាជារបបវាលពិឃាដ)

No formal education system (The regime was known to the world as the Killing Field)

- During the KR times, the country's infrastructure was destroyed, and the country's historical wheel was turned back to year zero (Ponchaud, 1978).
- No religion was practiced, no money was used, no education was implemented, no schools were built, there was no freedom of speech, and no respect for life.
- The KR was not at all interested in bureaucracy, or industrial production.

# ៣. សន្និដ្ឋាន

- ប្រទេសកម្ពុជាបានឆ្លងកាត់វិញ្ញាសាច្រើនបែបច្រើនយ៉ាងណាស់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ នៅពេលដែលប្រទេសជាតិមានសង្គ្រាម ជួបនឹងកលិយុគ ឬវិបត្តិម្តងៗ វិស័យអប់រំតែងតែទទួលរងនូវគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ។
- កម្ពុជាបានឆ្លងកាត់នូវដំណាក់កាលកសាងឡើងវិញនៃប្រព័ន្ធអប់រំជាច្រើនលើកច្រើនសារ ជាពិសេសគឺការកសាងឡើងវិញនូវប្រព័ន្ធអប់រំក្នុងរជ្ជកាលព្រះបាទអង្គឌួង ចាប់ពីពាក់កណ្តាលទី២នៃសតវត្សរ៍ទី១៩ ការធ្វើទំនើបកម្មវិស័យអប់រំក្នុងសម័យអាណានិគមនិយមបារាំង និងការពង្រឹងនិងពង្រីកប្រព័ន្ធអប់រំចាប់ពីពេលដែលកម្ពុជាទទួលបានឯករាជ្យពីបារាំងក្នុងឆ្នាំ១៩៥៣។
- ចាប់ពីការធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០មក សង្គ្រាមស៊ីវិលនិងអសន្តិសុខសង្គមក៏បានកើតមានឡើងធ្វើឱ្យវិស័យអប់រំដែលបានខំប្រឹងស្តារឱ្យងើបឡើងវិញ ត្រូវបានដួលរលំសារជាថ្មី រហូតដល់មានការបំផ្លិចបំផ្លាញចោលទាំងស្រុងនូវប្រព័ន្ធអប់រំ ដែលបង្កឡើងដោយរបបខ្មែរក្រហម ឬរបបកម្ពុជាប្រជាធិបតេយ្យ។